ក្រសួងការពារជាតិ

# សារថ្វាយព្រះពរ

## សូមក្រាបបង្គំទូលថ្វាយ
## ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈ

ក្នុងឱកាសដ៏នក្ខត្តឫក្ស នៃទិវាបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំ **មមែ** សប្តស័ក ពស ២៥៥៩ គ.ស ២០១៥ នេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងមូល សូម **ព្រះករុណា ថ្លៃវិសេស ជាអម្ចាស់ជីវិតតម្កល់លើត្បូង** ទ្រង់ព្រះមេត្តាប្រោស បរមរាជា-នុញ្ញាតឲ្យទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សម្តែងនូវកតញ្ញូ កតវេទិតាធម៌ដ៏ខ្ពង់ខ្ពស់បំផុត ថ្វាយចំពោះព្រះមហាករុណាទិគុណ នៃព្រះករុណាថ្លៃវិសេស ដែលបានបន្តនូវព្រះរាជមាគ៌ានយោបាយដឹកនាំដ៏ឧត្តុង្គឧត្តមពីព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "*ព្រះបរមរតនកោដ្ឋ* " នៃយើង។ ក្នុងព្រះរាជកិច្ចដ៏មមាញឹកក្នុងព្រះរាជបេសកកម្មដ៏មហាថ្លៃថ្លាក្នុង និងក្រៅប្រទេស របស់ព្រះអង្គ ក្នុងការបន្តធ្វើឲ្យមាននិរន្តរភាព និងលើកកម្ពស់កិត្យានុភាព នៃព្រះរាជាណាចក្រកម្ពុជានាំមកនូវសុខសន្តិភាព និងអភិវឌ្ឍន៍ប្រទេសជាតិមាតុភូមិឲ្យសម្បូររុងរឿង ដើម្បីបន្តលើកស្ទួយកិត្យានុភាព នៃព្រះរាជាណាចក្រកម្ពុជាឲ្យកាន់តែខ្ពស់ត្រដែត ត្រចះត្រចង់ល្បីរន្ទឺលើឆាកអន្តរជាតិ។

កត្តាទាំងនេះ បានធ្វើឲ្យទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ក៏ដូចជាប្រជារាស្ត្រខ្មែរទូទាំងប្រទេស មានមោទនភាពក្រៃលែង និងស្មោះស្ម័គ្រដង្ហែតាមព្រះរាជតម្រិះរបស់ព្រះអង្គជារៀងរហូត។

ក្នុងទិវាដ៏ថ្លៃថ្លានេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំអោនកាយវាចាចិត្តបួងសួង ចំពោះគុណបុណ្យព្រះរតនត្រ័យ ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោកមានទេវតារក្សាព្រះមហាស្វេតច្ឆត្រ ព្រមទាំងព្រះរាជតេជបារមី នៃព្រះអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ សូមទ្រង់ព្រះមេត្តាប្រោស ព្រះរាជទានប្រសិទ្ធពរជ័យ **បវរសួស្តី សិរីមង្គល វិបុលសុខ**

មហាប្រសើរ ថ្វាយចំពោះ **ព្រះករុណា ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជាជាទីសក្ការៈ សូមទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះជន្មាយុយឺនយូរ ព្រះរាជបញ្ញាញាណវាងវៃ ដើម្បីទ្រង់គង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់ត្រជុំ និងផ្ដល់នូវសេចក្ដីសុខក្សេមក្សាន្តចម្រើនរុងរឿង ដល់ប្រជានុរាស្ត្ររបស់ព្រះអង្គអស់កាលជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **ព្រះករុណា ជាអម្ចាស់ជីវិតតម្កល់លើត្បូង** ជាទីសក្ការៈ ទ្រង់ព្រះមេត្តាប្រោសទទួលនូវគារវភក្ដីភាពដ៏ខ្ពង់ខ្ពស់បំផុត អំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្ដីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស

សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**